**សាលាជាតិរដ្ឋបាលមូលដ្ឋាន**

# ក្របខ័ណ្ឌការងារ

## ទីប្រឹក្សារយៈពេលខ្លី ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ១. សេចក្តីផ្តើម

បន្ទាប់ពីប្រទេសជាតិទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញ តាមរយៈការអនុវត្ត "**នយោបាយឈ្នះ-ឈ្នះ**" ដែលផ្តួចផ្តើមគំនិត និងដឹកនាំអនុវត្តដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាចុងទសវត្សរ៍ទី ៩០ រាជរដ្ឋាភិបាលនីតិកាលទី២នៃរដ្ឋសភា បានសម្រេចចិត្តអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ឃុំ សង្កាត់ នាឆ្នាំ២០០១ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល នាឆ្នាំ២០០៨ ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាកំណែទម្រង់មួយដែលបានផ្តួចផ្តើម រៀបចំ ដឹកនាំ គ្រប់គ្រងដោយរាជរដ្ឋាភិបាល ផ្អែកតាមបរិបទផ្ទៃកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កម្ពុជា បានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបាននូវបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋានផ្សេងៗគ្នា ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ គុណភាពជីវិតរបស់សហគមន៍នៅមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធិភាព បរិយាប័ន្ន និងសមធម៌សង្គម។

ជាមួយនឹងសមិទ្ធផលដ៏ធំធេងក្នុងការអនុវត្តកំណែទម្រង់កន្លងមកនេះ នាចុងឆ្នាំ២០១៩ កំណែទម្រង់បានឈានដល់ចំណុចបត់ដ៏សំខាន់មួយទៀត គឺការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យក្លាយទៅជារដ្ឋបាលឯកភាពមួយ តាមរយៈការដាក់ចេញអនុក្រឹត្យលេខ១៨២ អនុក្រឹត្យលេខ១៨៣ និងអនុក្រឹត្យលេខ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយធ្វើសមាហរណកម្មការិយាល័យ អង្គភាពជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចូលទៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ដើម្បីជានាឱ្យរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចដំណើរការបានទៅតាមតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន ប្រកបដោយភាពរលូន ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ មានភារកិច្ចរៀបចំ និងផ្តល់នូវវគ្គបណ្តុះបណ្តាលទៅលើកិច្ចការចាំបាច់មួយចំនួន ដូចជាប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាដើម។

ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ត្រូវការជ្រើសរើសទីប្រឹក្សាបច្ចេកទេសជាតិរយៈពេលខ្លីចំនួន០១រូប ដើម្បីជួយរៀបចំខ្លឹមសារ ឬឯកសារមេរៀន វិធីសាស្ត្របណ្តុះបណ្តាល និងសម្ភារៈបណ្តុះបណ្តាល ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល។

## ២.គោលបំណងរួម

គោលបំណងរួមនៃកិច្ចការទីប្រឹក្សាបច្ចេកទេស គឺដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពមន្រ្តីទទួលបន្ទុកការងារហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈវគ្គបណ្តុះបណ្តាលមួយដែលមានឯកសារខ្លឹមសាមេរៀន វិធីសាស្ត្របណ្តុះបណ្តាល និងសម្ភារៈបណ្តុះបណ្តាលច្បាស់លាស់ ព្រមទាំងមានការអនុវត្តជាក់ស្តែង ដើម្បីឱ្យមន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុដែលបានទទួលការបណ្តុះបណ្តាល អាចបំពេញការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

## ៣. គោលបំណងជាក់លាក់នៃកិច្ចការទីប្រឹក្សាបច្ចេកទេស

គោលបំណងជាក់លាក់នៃកិច្ចការរបស់ទីប្រឹក្សាបច្ចេកទេសរួមមាន៖

- រៀបចំខ្លឹមសារឬឯកសារមេរៀនស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលគ្របដណ្តប់នូវគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំកម្មវិធីសិក្សា(Course Curriculum) សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំវិធីសាស្ត្របណ្តុះបណ្តាល(សៀវភៅប្លង់មេរៀន) រួមទាំងសម្ភារៈបណ្តុះបណ្តាលការអនុវត្តជាក់ស្តែង(សៀវភៅលំហាត់ ខ្លឹមសារលំហាត់ និងចម្លើយនៃលំហាត់នីមួយៗ) ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល ។

## ៤. ក្រុមគោលដៅ

ក្រុមគោលដៅនៃវគ្គបណ្តុះបណ្តាលបច្ចេកទេសស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺមន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៥. តួនាទី និងភារកិច្ចរបស់ទីប្រឹក្សាបច្ចេកទេស

- ពិនិត្យ និងសិក្សានូវរាល់លិខិតបទដ្ឋានគតិយុត្ត រួមទាំងឯកសារបណ្តុះបណ្តាលនានាដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំសេចក្តីព្រាងកម្មវិធីសិក្សា(Course Curriculum) សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលកម្មវិធីសិក្សានេះបរិយាយអំពី(១)ចំណងជើងមេរៀនជាក់លាក់ (២)គោលបំណងជាក់លាក់នៃមេរៀន (៣)ខ្លឹមសារសំខាន់នៃមេរៀន (៤)វិធីសាស្ត្រ (៥)សម្ភារៈឬឯកសារពាក់ព័ន្ធ និង(៦)ពេលវេលា
- រៀបចំសេចក្តីព្រាងខ្លឹមសារមេរៀនស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលគ្របដណ្តប់នូវគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំសេចក្តីព្រាងវិធីសាស្ត្របណ្តុះបណ្តាល(សៀវភៅប្លង់មេរៀន) រួមទាំងសម្ភារៈបណ្តុះបណ្តាល និងសម្ភារៈសម្រាប់ការអនុវត្តជាក់ស្តែង(សៀវភៅលំហាត់ ខ្លឹមសារលំហាត់ និងចម្លើយនៃលំហាត់នីមួយៗ) ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- អនុវត្តសាកល្បងនូវវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាថា ខ្លឹមសារមេរៀន វិធីសាស្ត្របណ្តុះបណ្តាល និងសម្ភារៈបណ្តុះបណ្តាលដែលបានរៀបចំឡើង មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចយល់ និងអនុវត្តបាន
- ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល។

## ៦. លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុកអំពីការកិច្ចការរបស់ទីប្រឹក្សាបច្ចេកទេសរួមមាន៖

- កម្មវិធីសិក្សា(Course Curriculum) សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ឯកសារមេរៀនស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលគ្របដណ្តប់នូវគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមានសេចក្តីពន្យល់ច្បាស់លាស់ និងងាយស្រួល
- សៀវភៅប្លង់មេរៀនសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលបានបរិយាយអំពីវិធីសាស្ត្របណ្តុះបណ្តាលច្បាស់លាស់ រួមទាំងសម្ភារៈបណ្តុះបណ្តាល

ស្លាយមេរៀន និងសម្ភារៈម្រាប់ការអនុវត្តជាក់ស្តែង(សៀវភៅលំហាត់ ខ្លឹមសារលំហាត់ និងចម្លើយនៃលំហាត់នីមួយៗ)

- វគ្គបណ្តុះបណ្តាលគ្រូបង្គោលបានរៀបចំ។

## ៧.គុណវឌ្ឍន៍របស់ទីប្រឹក្សាបច្ចេកទេស

ទីប្រឹក្សាបច្ចេកទេសដែលចាប់អារម្មណ៍នឹងមុខតំណែងខាងលើនេះ ត្រូវមានគុណវឌ្ឍន៍ដូចខាងក្រោមៈ

- បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ឬបណ្ឌិតក្នុងជំនាញផ្នែកហិរញ្ញវត្ថុសាធារណៈ គណនេយ្យ គោលនយោបាយសាធារណៈ ឬផ្នែកផ្សេងៗដែលពាក់ព័ន្ធ
- មានបទពិសោធន៍យ៉ាងហោច០៥ឆ្នាំ ក្នុងការរៀបចំ និងការផ្តល់វគ្គបណ្តុះបណ្តាល
- មានបទពិសោធន៍ពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- មានចំណេះដឹងច្បាស់លាស់អំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- មានជំនាញទំនាក់ទំនង និងសម្របសម្រួលល្អ
- មានចំណេះដឹងផ្នែកភាសារខ្មែរ និងអង់គ្លេសល្អ
- ស្ត្រីដែលមានសមត្ថភាពឆ្លើយតបទៅនឹងគុណវឌ្ឍន៍ខាងលើនេះ ត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងការទទួលបានកិច្ចសន្យាលើសេវាកម្មទីប្រឹក្សានេះ។

## ៨. កិច្ចការ និងក្របខ័ណ្ឌពេលវេលា

ក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តកិច្ចការទីប្រឹក្សាបច្ចេកទេសនេះមានរយៈពេល៣៥ថ្ងៃ ដែលសកម្មភាពទាំងនោះមានដូចក្នុងតារាងខាងក្រោមៈ

| ល.រ | សកម្មភាព និងលទ្ធផល | ចំនួនថ្ងៃ |
|---|---|---|
| ១ | ពិនិត្យមើលឯកសារពាក់ព័ន្ធនឹងមេរៀន | ០៣ថ្ងៃ |
| ២ | រៀបចំកម្មវិធីសិក្សា | ០២ថ្ងៃ |
| ៣ | រៀបចំសៀវភៅខ្លឹមសារមេរៀន | ១០ថ្ងៃ |
| ៤ | រៀបចំសៀវភៅមេរៀន ស្លាយមេរៀន ម្រាប់ការអនុវត្តជាក់ស្តែង | ១០ថ្ងៃ |
| ៥ | អនុវត្តវគ្គបណ្តុះបណ្តាលសាកល្បង | ០៥ថ្ងៃ |
| ៦ | ផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល | ០៥ថ្ងៃ |
| | **សរុប** | **៣៥ថ្ងៃ** |

## ៩. ថវិកា

ចំពោះថ្លៃសេវាប្រចាំថ្ងៃនៃទីប្រឹក្សាបច្ចេកទេសនេះ អាស្រ័យលើការពិភាក្សា ក្រោយពេលដែលបេក្ខជនត្រូវបានជ្រើសរើស ហើយវិធីសាស្ត្រនៃការទូទាត់ថវិកាជូនដល់ទីប្រឹក្សាបច្ចេកគឺធ្វើឡើងតាម០៣ដំណាក់កាលដូចខាងក្រោម៖

- ដំណាក់កាលទី១ ៖ ទូទាត់ថវិកា១០%នៃតម្លៃកិច្ចសន្យាសរុប គឺនៅពេលទីប្រឹក្សាបច្ចេកទេស បានបញ្ចប់លើការពិនិត្យឯកសារពាក់ព័ន្ធ និងការរៀបចំកម្មវិធីសិក្សារយៈពេល០៥ថ្ងៃ ដោយមានការឯកភាពពីអ្នកគ្រប់គ្រងកិច្ចសន្យាសេវាទីប្រឹក្សាបច្ចេកទេស
- ដំណាក់កាលទី២ ៖ ទូទាត់ថវិកា៦០%នៃតម្លៃកិច្ចសន្យាសរុប គឺនៅពេលទីប្រឹក្សាបច្ចេទេស បានបញ្ចប់ការរៀបចំសៀវភៅខ្លឹមសារមេរៀន និងសៀវភៅប្លង់មេរៀន ស្លាយមេរៀន និងសម្ភារៈសម្រាប់អនុវត្តជាក់ស្តែង ដោយមានការឯកភាពពីអ្នកគ្រប់គ្រងកិច្ចសន្យាសេវាទីប្រឹក្សាបច្ចេកទេស
- ដំណាក់កាលទី៣ ៖ ទូទាត់ថវិកា៣០%នៃតម្លៃកិច្ចសន្យាសរុប គឺនៅពេលទីប្រឹក្សាបច្ចេកទេសបានបញ្ចប់ការអនុវត្តវគ្គបណ្តុះបណ្តាលសាកល្បង ការកែសម្រួលសៀវភៅខ្លឹមសារមេរៀន និងសៀវភៅប្លង់មេរៀន និងការផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលនៃសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**១០. អ្នកគ្រប់គ្រងកិច្ចសន្យា**

សេវាទីប្រឹក្សានេះគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានគ.ជ.អ.ប។ ទីប្រឹក្សាបច្ចេកទេសត្រូវរាយការណ៍រាល់លទ្ធផល ឬបញ្ហាទាំងអស់ពាក់ព័ន្ធទៅនឹងកិច្ចការទីប្រឹក្សាបច្ចេកទេសនេះជូន **លោក សូ មុនីរក្សា** នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន និងជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។